មជ្ឈមណ្ឌលដើម្បីសន្តិភាព និង អភិវឌ្ឍន៍

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

Centre for Peace and Development (CPD)

Cambodia Development Resource Institute (CDRI)

# កំណត់ហេតុកិច្ចប្រជុំអ្នកបច្ចេកទេស

# ស្តីពី បញ្ជីឈ្មោះអ្នកបោះឆ្នោត

## ខប់សែល ដំណាក់កាលទី ២

## COPCEL Phsase II

*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme (UNDP)**

## ១. សាវតា និង គោលបំណង

អង្គប្រជុំក្រុមអ្នកបច្ចេកទេសបានដំណើរការនៅ នៅថ្ងៃទី ១០ ខែឧសភា ឆ្នាំ ២០០៧ នៅ វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា រៀបចំដោយ យន្តការបង្ការទំនាស់នៅក្នុងការបោះឆ្នោតនៅកម្ពុជា (ខប់សែល) ។ អញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំនេះ មានតំណាងមកពី គណកម្មាការជាតិរៀបចំការបោះឆ្នោត ក្រសួងមហាផ្ទៃ គណបក្សនយោបាយ និងសង្គមស៊ីវិល ព្រមទាំង UNDP ដែលជាម្ចាស់ជំនួយគាំរោងនេះផងដែរ ។

អង្គប្រជុំក្រុមអ្នកបច្ចេកទេសនេះធ្វើឡើងគឺដើម្បីរិះរកដំណោះស្រាយលើបញ្ហា **"បញ្ជីអ្នកបោះឆ្នោត"** ។ ប្រធានបទនេះត្រូវបានចាត់ទុកជាប្រធានបទស្នូលសំរាប់ជាជំហានទៅរកដំណោះស្រាយលើបញ្ហាដទៃទៀត ដែលមាននៅក្នុង ដំណើរការបោះឆ្នោត ។ ប្រធានបទនេះបានផុសចេញពីកិច្ចប្រជុំអ្នកពាក់ពន្ធ័ថ្នាក់ខ្ពស់លើការរៀបការបោះឆ្នោតឃុំសង្កាត់២០០៧ នៅថ្ងៃទី ២០ ខែមេសា ២០០៧ នៅសណ្ឋាគារកាំបូឌីយ៉ាណា ។ បញ្ហាបញ្ជីរឈ្មោះអ្នកបោះឆ្នោតបានទទួលស្គាល់ថា បញ្ជីរឈ្មោះប៉ោង មិនសុក្រិត្រ សរសេរខុសច្រើនរវាងស្ថិតិក្រុមប្រឹក្សាឃុំសង្កាត់ ប៉ូលីស និង គជប ។ ដរាបណាបញ្ហាបញ្ជីរអ្នកបោះឆ្នោតមិនអាចដោះស្រាយបាននោះទេ យន្តការនៃការបោះឆ្នោតនឹងនៅតែមានការទទួលការរិះគន់ ហើយនឹងជួបប្រទះការលំបាកគ្រប់ដំណាក់កាលបោះឆ្នោត ។ ម្យ៉ាងវិញទៀត អ្នកមិនមកចូលរួមបោះឆ្នោតមានតួរលេខរហូតដល់ទៅជាង ៣២ ភាគរយ គឺអាចបណ្ដាលមកពីទាំងកត្តាបញ្ជីរប៉ោង និងអ្នកបានមិនចូលរួមបោះឆ្នោត ។ លទ្ធផលដែលទទួលបានពីក្រុមពិភាក្សាក្រុមអ្នកបច្ចេកទេសនេះនឹងដាក់ជូនទៅ គជប ដើម្បីធ្វើការសំរាបសំរួលលើបញ្ហា ក៏ដូចជាដំណោះស្រាយដែលបានលើកឡើងនៅក្នុងអង្គប្រជុំនេះ ។

## ២. បញ្ហា និង សំនើឱ្យមានដំណោះស្រាយ

អ្នកចូលរួមបានលើកឡើងថា បញ្ជីរឈ្មោះអ្នកបោះឆ្នោតប៉ោងដោយសារមូលហេតុដូចជា ឈ្មោះស្ទួន ឈ្មោះខ្មោច ឈ្មោះអ្នកចំណាកស្រុក និងឈ្មោះខុស ។ **បញ្ហាឈ្មោះនិងទិន្នន័យខុស** គឺ ប្រហែលជាបណ្ដាលមកពីស្មៀនឃុំ ដែលកាលពីឆ្នាំ ២០០៦ អ្នកបោះឆ្នោតបានកែតំរូវទិន្នន័យរបស់គាត់ហើយនៅក្នុងបណ្ណ័ពតិមានលើកទី ១ ប៉ុន្តែពេលចេញប័ណ្ណពតិមានលើកទី ២ ឈ្មោះមួយចំនួននោះនៅតែខុស ។ នេះមានន័យថា ពេលស្មៀនកែរួច បញ្ជីរបានផ្ញើទៅឱ្យ គជប ប៉ុន្តែ មិនដឹងថា ស្មៀនសរសេរខុសនៅពេលកែ រឺ កំហុសកើតមាននៅមជ្ឈមណ្ឌលកំព្យូទ័ររបស់ គជប នោះទេ ។ ដូច្នេះ ឈ្មោះកែរួច ពេលត្រឡប់មកវិញនៅតែខុសដដែល ។ ឬសគល់នៃបញ្ហាគឺ ស្មៀនអាចកែចំលងឈ្មោះលើបញ្ជីរមួយហើយ ប៉ុន្តែមិនតំរូវឱ្យថតចំលងទេ ។ ស្មៀនត្រូវចំលងដោយសរសេរដៃជាច្រើនច្បាប់ ដើម្បីបញ្ជូនទៅ គជប ។ ដូច្នេះដំណោះស្រាយគឺថា បើស្មៀនកែក្នុងបញ្ជីរមួយហើយ រួចយកបញ្ជីរនោះថតចំលងបញ្ជូនទៅ គជប ដើម្បីឱ្យ គជប កែតំរូវឱ្យត្រឹមត្រូវវិញគឺ វាមិនបណ្ដាលឱ្យខុសនោះទេ ។ យ៉ាងណាមិញទាក់ទងទៅនឹងការថតចំលងបញ្ជីដែលធ្វើការកែតំរូវហើយនោះ គួរត្រូវទទួលខុសត្រូវដោយ គជប ស្មៀនមិនគួរជាអ្នកថតចំលងនោះទេ ។

នេះជាការមួយជួយសំរួលដល់ស្មៀន ហើយជាការមួយជួយឱ្យធ្វើកាងារបានលឿន និងមានប្រសិទ្ធភាព ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏បញ្ហាអក្សររបស់ស្មៀនដែលកែចូលក្នុងច្បាប់ទីមួយនោះ គួរសរសេរឱ្យច្បាស់ ជៀសវាងមានបញ្ហា ។ ឧទាហរណ៍ថា ឈ្មោះ **លាយ** បើសរសេរមិនច្បាស់ អាចទៅជា **ណយ** ។ ដូច្នេះ ស្នើឱ្យ គជប ចេញជាសេចក្តីជូនដំណឹងឱ្យច្បាស់ដល់ស្មៀនពីអក្សរដែលប្រហាក់ប្រហែលគ្នា ។ ទោះបីអក្សរគាត់មិនស្អាតក៏ដោយ ក៏គួរតែសរសេរឱ្យច្បាស់ ចៀសវាងច្រឡំ ។ បញ្ហាកំហុសឈ្មោះក៏អាចបណ្តាលមកពី **មជ្ឈមណ្ឌលកុំព្យូទ័រ** គជប ផងដែរ ។ គជប គួរធ្វើការត្រួតពិនិត្យនិងពង្រឹងមជ្ឈមណ្ឌលកុំព្យូទ័ររបស់ខ្លួនធ្វើយ៉ាងណាឱ្យការបញ្ចូលទិន្នន័យ បានសុក្រឹត្រ ។

**ចំពោះដំណោះស្រាយឈ្មោះស្ទួន** ដែលរកឃើញ គជប គួរផ្តល់ពតិមានទៅអ្នកបោះឆ្នោត ជាអ្នកសំរេចចិត្តលប់ឈ្មោះណាដែលគាត់មិនប្រើប្រាស់នៅថ្ងៃបោះឆ្នោត ។ ទង្វើនេះអាចកាត់បន្ថយបញ្ជីរឈ្មោះប៉ោង និងជួយសំរួលដល់ការចូលរួមបោះឆ្នោតផង ។ ចំពោះការរកឃើញថា ឈ្មោះខ្មោចដែលមានតែឈ្មោះតែមិនមានមនុស្ស គឺមានតែអាជ្ញាធរមូលដ្ឋានទេ ដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ អាចដោះស្រាយចំពោះករណីនេះបាន ដោយធ្វើស្ថិតិឡើងវិញ ។

**ករណីអ្នកចុះឈ្មោះបោះឆ្នោតថ្មី** ស្នើឱ្យ គជប កំណត់លេខកូដការិយាល័យសំរាប់អ្នកចុះឈ្មោះបោះឆ្នោតថ្មី និងស្នើឱ្យរក្សាលេខកូដនៅដដែល នៅពេលដែលចេញនៅក្នុងបញ្ជីរ ។ ការដូរការិយាល័យបោះឆ្នោត ពាក់ព័ន្ធទៅដល់ការទៅបោះឆ្នោត ។ អ្នកបោះឆ្នោតពិបាករកការិយាល័យ ដោយសារការដូរលេខកូដថ្មី ដូច្នេះ ពួកគាត់អាចបោះបង់ការបោះឆ្នោត ។ ដំណោះស្រាយគឺអ្នកដែលចុះឈ្មោះថ្មីគឺដាក់នៅការិយាល័យថ្មី ហើយអ្នកចាស់នៅរក្សាដដែល ដើម្បីឱ្យមានភាពងាយស្រួលចំណាំ ។ បញ្ហានេះ វាពាក់ពាន្ធ័នឹងចំនួនអ្នកចុះឈ្មោះដែលកំណត់តាមការិយាល័យបោះឆ្នោតនីមួយៗឱ្យទទួលចុះឈ្មោះអ្នកបោះឆ្នោតយ៉ាងច្រើនបំផុតត្រឹម ៧០០ នាក់ ។ ដូច្នេះ ពេលឈ្មោះលើសពី ៧០០ នាក់ ស្មៀនមិនដឹងធ្វើយ៉ាងដូចម្តេចបន្ត ហើយក៏ពុំមានការណែនាំដែរ ។ ដំណោះស្រាយ គឺស្នើឱ្យ គជប បន្ថែមឃ្លាបន្តនៅក្នុងសេចក្តីណែនាំថា "បើសិនមានអ្នកចុះឈ្មោះបោះឆ្នោតលើសពី ៧០០ នាក់ ត្រូវចុះឈ្មោះអ្នកលើសទាំងនោះនៅការិយាល័យថ្មី" ។

ចំពោះ**អ្នកផ្លាស់ប្តូរទីលំនៅ** រឺឈ្មោះអ្នកស្លាប់ គជប គួរប្រគល់ការងារនេះឱ្យក្រុមប្រឹក្សាឃុំធ្វើជំរឿនដែលសមាជិកក្រុមប្រឹក្សាឃុំសង្កាត់មកគណបក្សច្រើន ហើយឱ្យទៅជាការងារចំរុះ ដែលមិនចង់ឱ្យមានការធ្វើការសំរេចចិត្តតែប្រធានក្រុមប្រឹក្សាឃុំសង្កាត់ រឺ មេឃុំចៅសង្កាត់មួយរូបនោះទេ ។ វាគួរតែឱ្យមានការចូលរួមក្នុងដំណើរការចុះឈ្មោះនៅក្នុងដំណើរការជំរឿនប្រជាជននៅក្នុងឃុំសង្កាត់របស់ខ្លួន ដើម្បីស្រាវជ្រាវរកអ្នកដែលស្លាប់អ្នកផ្លាស់ប្តូរទីលំនៅឱ្យមានការទទួលខុសត្រូវជារួម ។

**បញ្ហាចំណាកស្រុក** អាចបណ្តាលឱ្យស្ថិតិក្នុងបញ្ជីរខុស ហើយមានឈ្មោះជាន់គ្នា និង មិនអាចចូលរួមបោះឆ្នោតបានដែរ ។ ដំណោះស្រាយមួយចំនួនអាចធ្វើទៅបានដោយក្រុមប្រឹក្សាឃុំអណត្តិថ្មី គឺវិធីអង្កេតស្ថិតិដោយសហការណ៍

ជាមួយមេភូមិដើម្បីរកឱ្យឃើញចំនួនអ្នកចំណាកស្រុក អ្នកស្លាប់ និងឈ្មោះស្ទួន តាមភូមិនីមួយៗ ។ លទ្ធផល គេអាចធ្វើជាបញ្ជីរមួយផ្ញើឱ្យ គជប រឺ បិទផ្សាយនៅសង្កាត់ ។ ដោយប្រៀបធៀបគ្នាជាមួយបញ្ជីរបោះឆ្នោតដែលគូសឈ្មោះសំគាល់ពេលបោះឆ្នោតថា បានបោះនោះ គជប អាចនឹងរកអ្នកមិនបានបោះឆ្នោត អ្នកស្លាប់ អ្នកធ្វើចំណាកស្រុក និងឈ្មោះជាន់គ្នាឃើញ ហើយក្រុមប្រឹក្សាឃុំទទួលខុសត្រូវ ដើម្បីផ្ទៀងផ្ទាត់ផ្សព្វផ្សាយ មុននឹងលុបឈ្មោះចេញពីបញ្ជីរ ។ ការលុបទៀតសោធ គឺមិនត្រូវបំបាត់ឈ្មោះនោះពីបញ្ជីរទេ វាចាំបាច់ត្រូវឆូតកាត់ឈ្មោះ ដើម្បីទុកជាការផ្ទៀងផ្ទាត់ ។

**រយៈពេលនៃការចុះឈ្មោះ** ក៏មានជះឥទ្ធិពលដល់ដំនើរការធ្វើឱ្យបញ្ជីរបានស្អាតដែរ ។ ដូច្នេះ រយៈពេលនៃការចុះឈ្មោះយូរ នាំឱ្យស្មៀនមានពេលពិនិត្យផ្ទៀងផ្ទាត់ បានច្រើនជាង ។ ការងារចុះឈ្មោះដែលស្មៀនធ្វើគឺ ដំណើរការព្រមគ្នាជាមួយការងារផ្សេងទៀត ហើយរយៈពេលខ្លី ដូច្នេះ គាត់ធ្វើការងារផ្សេងៗច្រើនម៉ោង គាត់មិនអាចមកទទួលការងារតែមួយមុខនេះឱ្យដំនើការល្អទេ ។ រយៈពេលចុះឈ្មោះស្នើឱ្យមានរយៈពេលមួយឆ្នាំពេញ ។

**បញ្ហាទំរង់ ១០១៨** ដែលចេញឱ្យអ្នកគ្មានអត្តសញ្ញាណបណ្ណ័រឺឈ្មោះខុសនោះ ក៏បណ្តាលឱ្យមានបញ្ហាដល់បញ្ជីរអ្នកបោះឆ្នោតដែរ ។ គជប គួរតែស្នើឱ្យមេឃុំធ្វើបញ្ជីរឈ្មោះ ដែលបានចេញទំរង់ ១០១៨នេះ ។ តួរលេខសរុបអ្នកទទួលទំរង់ ១០១៨ ទូទាំងប្រទេសមុនថ្ងៃមុនបោះឆ្នោត អាចផ្តល់ពត៌មានពីបញ្ហាខុសឈ្មោះរឺបញ្ហាផ្សេងទៀតដែលខុសឆ្ងាយពីសេចក្តីណែនាំរបស់ គជប ដូចជាមិនមានសិទ្ធិរឺឯកសារបោះឆ្នោតសោះ ហើយគាត់ទៅធ្វើទំរង់ ១០១៨ ដើម្បីបានបោះឆ្នោតដែរជាដើម ។ ដូច្នេះជាការចាំបាច់ណាស់ មេឃុំគួរតំរូវឱ្យធ្វើបញ្ជីរអ្នកដែលទទួលបានទំរង់ ១០១៨ ។ បញ្ហាមួយទៀតរបស់ទំរង់ ១០១៨ គឺ រូបថតដែលជាបញ្ហាធ្ងន់ធ្ងរសំរាប់ប្រជាពលរដ្ឋរស់នៅតំបន់ឆ្ងាយពីទីប្រជុំជន ។ ដើម្បីបានរូបថត ជួនកាលប្រជាពលរដ្ឋត្រូវចំណាយច្រើនធ្វើដំណើរទៅថតរូប ។ ឧទាហរណ៍ ភូមិមួយចំងាយ ១០០ គ.ម ពីទីប្រជុំជន ប្រជាពលរដ្ឋត្រូវចំណាយសោហ៊ុយច្រើនដើម្បីទៅដល់ ជួនកាលមិនដឹងទៅថតនៅទីណាផង។ ដូច្នេះស្នើ គជប ផ្តល់ម៉ាស៊ីនប្រចាំនៅតាមឃុំ ដើម្បីថតរូបឱ្យប្រជាពលរដ្ឋ នៅពេលគាត់បញ្ជាក់ទំរង់ ១០១៨ ។

**អត្តសញ្ញាណប័ណ្ណ** វាមិនមែនត្រឹមតែធ្វើឱ្យបញ្ជីរប៉ោងនោះទេ វាបង្កឱ្យមានអ្នកមិនទៅ និងមិនបានបោះឆ្នោតផងដែរ ។ ការឈប់ប្រើប័ណ្ណបោះឆ្នោត ហើយមកប្រើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ បានចោទជាបញ្ហាដល់អ្នកគ្មានអត្តសញ្ញាណប័ណ្ណ គួបផ្សំនឹងការលំបាកក្នុងការបំពេញទំរង់ ១០១៨ ដូចជាទាមទាររូបថត អ្នកមានសិទ្ធបោះឆ្នោតក៏បោះបង់ចោលសិទ្ធិបោះឆ្នោត ដែលចំនុចនេះ ធ្វើឱ្យអត្រាអ្នកបោះឆ្នោតថយចុះ ។ ដូច្នេះ សំនើរឱ្យក្រសួងមហាផ្ទៃធ្វើអត្តសញ្ញាណប័ណ្ណដែលនៅសេសសល់ឱ្យទាន់ពេលវេលាបោះឆ្នោត ។ ទោះបីជាអត្តសញ្ញាណប័ណ្ណចេញដោយក្រសួងមហាផ្ទៃក៏ដោយ ក៏មានការលើកឡើងពីករណីក្លែងក្លាយអត្តសញ្ញាណប័ណ្ណដែលធ្វើឱ្យដំណើរការចេញបណ្ណ័របស់ក្រសួងមិនអាចទុកចិត្តបានឡើយ ។ ករណីក្លែងក្លាយអាច ទីមួយ អាចចេញដោយក្លែងក្លាយពីមន្ត្រីប៉ូលីស ទីពីរ គេអាចធ្វើដោយខ្លួនឯងដោយគ្រាន់តែស្កែន អត្តសញ្ញាណប័ណ្ណណាមួយចូលក្នុងកុំព្យូទ័រ រួចកែទិន្នន័យ ទាំងលេខកូដដាក់រូបថតថ្មី រួចគេយកទៅបោះពុម្ពចេញមួយសន្លឹកជាអត្តសញ្ញាណប័ណ្ណយ៉ាងស្អាត ដើម្បីយកទៅរកកាងារធ្វើ ។

ចំណោយធ្វើរបៀបនេះអស់តិចបំផុត ។ ម្យ៉ាងវិញទៀត អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរនេះ គួរតំរូវឱ្យប្រើជាសកល មិនគួរមានប្រើបណ្ណ័ផ្សេងៗ ដូចជា កាតប៉ូលីស រឺកាតទាហាននោះទេ ។ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរនេះស្របច្បាប់ជាងបណ្ណ័ផ្សេងៗហើយមិនបង្កភាពរើសអើងឡើយ ។ ម្យ៉ាងវិញទៀត ដើម្បីរកឈ្មោះខ្មោចរឺឈ្មោះស្ទួន គួរងាកមករកការប្រើប្រាស់ **ស្នាមមេដៃ** ជាគោលគ្រឹះ រួមជាមួយនឹងអត្តសញ្ញាណបណ្ណ័សញ្ជាតិខ្មែរ ព្រោះស្នាមមេដៃនេះឆ្លើយបានត្រឹមត្រូវណាស់ ទោះជាមានមនុស្សទូទាំងពិភពលោក ក៏មិនមានស្នាមមេដៃដូចគ្នានោះដែរ ។ បទពិសោធន៍ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី សុខ អាន ដែលលោកមានមោទនៈភាពចំពោះការរកឃើញ និងលុបឈ្មោះខ្មោចពីបញ្ជីរមន្ត្រីរាជ្យការ ពី ៩៦ម៉ឺននាក់ មកសល់ត្រឹម ៣២ម៉ឺន នាក់ គឺ ដោយសារ ស្នាមមេដៃនេះឯង ។

**ការបោះឆ្នោតគឺ ជាសិទ្ធិជាពលរដ្ឋ** ហើយវាមិនមែនជាកាតព្វកិច្ចនោះទេ ។ ដូច្នេះ ប្រជាពលរដ្ឋមិនមានឆន្ទៈតស៊ូនឹងការរាំងស្ទះមួយចំនួន ហើយបោះបង់ការចូលរួមបោះឆ្នោត ។ ដូច្នេះ ដើម្បីឱ្យអត្រាអ្នកបោះឆ្នោតកើនឡើង ការចូលរួមបោះឆ្នោតគួរចាត់ទុកជាកាតព្វកិច្ចដូចប្រទេសមួយចំនួនមាន ថៃឡង់ដ៏ និងអូស្ត្រាលី ដែលដាក់ពិន័យចំពោះការខកខានមិនបានបោះឆ្នោត ។ ប្រទេសកម្ពុជានៅកាលៈទេសៈនេះប្រហែលមិនអាចធ្វើបានទេ ប៉ុន្តែ គួរតែពិចារណារដាក់វាកាតព្វកិច្ច ហើយនៅពេលណាចំនួនអ្នកបោះឆ្នោតកើនឡើង និងអ្នកបោះឆ្នោតយល់ដឹងច្រើន កាតព្វកិច្ចនេះត្រូវដកចេញក៏បានដែរ ។

**ការឃោសនា និងការផ្សព្វផ្សាយ**របស់ គជប មិនទាន់ទូលំទូលាយទេ ។ ចំនុចដែលល្អគឺការចែក**ប័ណ្ណពតិមាន**អ្នកបោះឆ្នោត ដែលវាជួយអ្នកបោះឆ្នោតច្រើនណាស់ ។ ប័ណ្ណពតិមានបានជួយឱ្យអ្នកបោះឆ្នោតស្គាល់ការិយាល័យបោះឆ្នោត និងឱ្យដឹងលេខកូដជាដើម ថ្វីត្បិតតែប្រជាពលរដ្ឋខ្លះនៅច្រលំយកប័ណ្ណពតិមាននេះទៅបោះឆ្នោតជំនួសអត្តសញ្ញាណបណ្ណ័ជាតិក៏ដោយ ។ ដូច្នេះ ដំណើរការចែកបណ្ណ័ពតិមានគួររក្សាទុក ។ ហើយចំពោះបញ្ហាដែលថាលុបប័ណ្ណពតិមាន រួចចង់បង្កើតបណ្ណ័ អ្វីទៀតជំនួសនោះ វានាំឱ្យមានការលំបាក ពីព្រោះថា វាដូចជាលុបប័ណ្ណហើយបង្កើតប័ណ្ណវិញ ។ គជប គួរខិតខំចែកឱ្យបាន ១០០ ភាគរយ ដោយរកវិធីសាស្ត្រតាមដានឱ្យច្បាស់ពីមូលហេតុដែលមិនបានទទួលប័ណ្ណពតិមាន រឺ ដោយសារ ស្លាប់ រឺផ្លាស់ប្តូរទីលំនៅ ជៀសវាងទុកចោលនៅស្នាក់ការឃុំសង្កាត់ដោយមិនមានមូលហេតុច្បាស់លាស់ ។ ទោះជាមានការយល់ស្របគ្នាភាគច្រើនពីអត្ថប្រយោជន៍នៃបណ្ណ័ពតិមាន ក៏មានមតិមួយភាគលើកស្នើឡើងឱ្យលុបចោលប័ណ្ណពតិមាននេះដែរ។

បើក្រសួងមហាផ្ទៃអាចធានាបានថា ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឱ្យបានល្អនិងត្រឹមត្រូវ ការសំអាតបញ្ជីរអ្នកបោះឆ្នោតអាចដោះស្រាយបាន ៧០ ភាគរយ ដោយគ្រាន់តែផ្ទេរបញ្ជីរអត្តសញ្ញាណប័ណ្ណទៅឱ្យ គជប ហើយ គជប ផ្ទៀងតាមលេខកូដដើម្បីរកអ្នកឈ្មោះខុស និងឈ្មោះស្ទួនជាដើម ។ លើសពីនេះទៅទៀត គជប អាចផ្ទៀងផ្ទាត់កាន់តែច្បាស់ទៀតជាមួយ "បញ្ជីរស" ។ បញ្ជីរស គឺ ជាបញ្ជីរដែលចុះឈ្មោះអ្នកបោះឆ្នោតនៅថ្ងៃបោះឆ្នោតដោយមិនចាំបាច់មានឈ្មោះសំរាប់ឱ្យផ្ទៀងផ្ទាត់ជាមុន ។ ដើម្បីឱ្យបាន បញ្ជីរស គឺ នៅពេលបោះឆ្នោត អ្នកបោះឆ្នោត

យកអត្តសញ្ញាណប័ណ្ណ មកកត់ឈ្មោះ អត្តលេខ ដាក់លេខរៀង លេខការិយាល័យ រួចផ្ដិតមេដៃ ជាការស្រេច ។ បញ្ជីរនេះអាចផ្ទៀងផ្ទាត់បាន ទាំងការបន្លំ ហើយអាចរកអ្នកធ្វើក្លែងក្លាយ និង ដាក់ទោសបានផងដែរ ។

ទោះជាយ៉ាងនេះក្ដី ក៏មតិមួយបានលើកឡើងពីការព្រួយបារម្ភលើ និតិវិធី គជប ក្នុងការទទួលយកអនុសាសន៍ និងដំណោះស្រាយដែលបានលើកឡើងដែរ ។ ការអះអាងបានបញ្ជាក់ថា គជប មិនធ្លាប់រៀបចំកិច្ចប្រជុំជាមួយគណបក្សនយោបាយ អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិលឱ្យបានរៀបរយទេ ហើយភាគច្រើន គជប គ្រាន់តែអញ្ជើញគណបក្សនយោបាយ និងសង្គមស៊ីវិលទៅស្ដាប់ គជប ធ្វើសន្និសីទសារពតិមាន ដែលមិនមានកំណត់ហេតុប្រជុំនូវអ្វីដែលចូលរួមបាននិយាយនោះទេ ។ នេះជាការបង្ហាញថា គជប មិនទទួលខុសត្រូវ ទោះជាមានការលើកឡើងរួចមកហើយជាច្រើនដង ពីបញ្ជីរបញ្ហាឈ្មោះអ្នកបោះឆ្នោត បញ្ហាឈ្មោះខុសអក្ខរាវិរុទ្ធ និងឈ្មោះខ្មោចក្ដី ។

## ៣. យោបល់តំណាង គជប

ជំហររបស់ គជប គឺ កំពុងយកចិត្តទុកដាក់ដោះស្រាយបញ្ហាមួយចំនួនដែល គជប ទទួលបានពីកិច្ចប្រជុំទាំងឡាយដែលពាក់ពន្ធ័នឹងការបោះឆ្នោត ទាំងការប្រជុំ ពីបីលើក របស់ខ្លួន និងការប្រជុំផ្សេងទៀត ។ គជប យល់ថាប្រធានបទបញ្ជីរអ្នកបោះឆ្នោតនេះជាគឺប្រធានល្អសំរាប់គោលបំណងធ្វើយ៉ាងណាបញ្ចប់កង្វល់ទាំងឡាយ ដែលដូចបានលើកឡើងខាងដើមនេះ ។ ទន្ទឹមនឹងនេះដែរ គជប កំពុងយកចិត្តទុកដាក់លើបញ្ហាបញ្ជីរអ្នកបោះឆ្នោត និងបានចាត់វិធានការណ៍ខ្លះៗដែលបានរៀបចំគំរោងរួចហើយ ។ ប៉ុន្តែ លទ្ធផលយ៉ាងណានោះ គជប មិនទាន់ដឹងនៅឡើយ។

**បញ្ហាចំនួនប្រជាពលរដ្ឋអញ្ជើញទៅបោះឆ្នោតមានចំនួនតិច** មានបញ្ហា ២ គឺ បញ្ជីរឈ្មោះប៉ោង ហើយមួយទៀតនោះគឺប្រជាពលរដ្ឋមិនបានទៅចូលរួមបោះឆ្នោត ។ បញ្ហាបញ្ជីរឈ្មោះប៉ោងនេះគឺ លោក លោកស្រីបានលើកឡើងហើយថា ដោយសារតែប្រជាពលរដ្ឋផ្លាស់ប្ដូរទីលំនៅ ។ នៅពេលប្រជាពលរដ្ឋផ្លាស់ប្ដូរទីលំនៅ គាត់ទៅចុះឈ្មោះនៅកន្លែងថ្មី ប៉ុន្តែ គាត់មិនបានលុបឈ្មោះនៅកន្លែងចាស់បានទេ ។ ម្យ៉ាងវិញទៀត បើគាត់មិនដឹងលេខការិយាល័យកន្លែងចាស់ទេ គាត់ក៏មិនអាចលុបឈ្មោះពីបញ្ជីរនៅការិយាល័យចាស់ដែរ ។ ដូច្នេះ បើសិនជាគាត់មិនអាចលុបឈ្មោះវាធ្វើឱ្យឈ្មោះគាត់នៅមានពីរកន្លែងដែលធ្វើបញ្ជីរបោះឆ្នោតប៉ោង ។ បញ្ហាមួយទៀតគឺថា អត្រាមរណភាពមានប្រមាណជាង ១ ភាគរយក្នុង ១ ឆ្នាំ ។ ប្រជាពលរដ្ឋ ដែលបានស្លាប់ មិនទាន់បានបំពេញទំរង់បែបបទគ្រប់គ្រាន់តាមផែនការនោះទេ ។ ករណីមួយទៀត គឺ កម្មកររោងចក្រដែលមានសិទ្ធិចុះឈ្មោះនៅកន្លែងធ្វើការបាន ។ ដូច្នេះ ពួកគាត់ភាគច្រើនអាចចុះឈ្មោះ ពីរបី ដង។ ភាគច្រើន គាត់មានឈ្មោះក្នុងបញ្ជីរបោះឆ្នោតរួចហើយ ប៉ុន្តែដល់ថ្ងៃចុះឈ្មោះបោះឆ្នោត ក្រសួងសង្គមកិច្ច រឺខាងរោងចក្រអនុញ្ញាតឱ្យគាត់សំរាកពីការងារទៅចុះឈ្មោះ ប៉ុន្តែ តំរូវឱ្យមានបង្កាន់ដៃរចុះឈ្មោះដើម្បីទូទាត់ការឈប់សំរាក់នេះ ។ ដូច្នេះ ដើម្បី ទទួលបានឱកាសល្អទៅលេងផ្ទះហើយមានបង្កាន់ដៃមកជាមួយគាត់ត្រូវបង្ខំចិត្តចុះឈ្មោះម្ដងទៀត ។ ទង្វើនេះទើបធ្វើឱ្យមានបញ្ហាបញ្ជីរឈ្មោះប៉ោងមួយចំនួនទៀត។

គជប ប៉ាន់ស្មានថា ឈ្មោះប្រជាពលរដ្ឋដែលធ្វើឱ្យបញ្ជីរប៉ោងមានប្រមាណជាង ១០ភាគរយ ហើយប្រជាពលរដ្ឋជាង ១០ភាគរយ ទៀតមិនបានទៅបោះឆ្នោត ស្របទៅនឹងការស្រាវជ្រាវខុមហ្វ្រែលដែរ ។ នៅក្នុងនោះ ភាគច្រើនគឺជាកម្មករមិនបានវិលត្រលប់ទៅបោះឆ្នោត ដោយសារសោហ៊ុយធ្វើដំនើរនៅថ្ងៃបោះឆ្នោតបានឡើងថ្លៃ ។ ផ្ទុយពីកម្មកររោងចក្រដែលបានអនុញ្ញាតឱ្យឈប់សំរាកទៅបោះឆ្នោត កម្មករមួយចំនួនទៀតដូចជានៅតាមភោជនីយដ្ឋាន សិប្បកម្ម និងឧស្សាហកម្មតូចៗ មិនបានអនុញ្ញាតឱ្យឈប់សំរាកទេ ។ ដោយសារ បញ្ហាសោហ៊ុយធ្វើដំណើរផង ហើយបើទៅបោះឆ្នោត ចៅកែកាត់ប្រាក់ខែផង ដូច្នេះគាត់មិនបានត្រលប់ទៅបោះឆ្នោតនៅតាមគោលដៅចុះឈ្មោះទេ ។ បញ្ហាមួយទៀតនោះគឺ ប្រជាពលរដ្ឋនៅតាមជួរព្រំដែនដូចជា ខេត្តបន្ទាយមានជ័យ ឧត្តមានជ័យ កោះកុង បាត់ដំបង ភាគច្រើនទៅរកស៊ីនៅថៃ ដូច្នេះការវិលត្រឡប់នមកវិញដើម្បីបោះឆ្នោត មានចំនួនតិច ។

វិធានការណ៍ចំពោះបញ្ជីរប៉ោង គជប នឹងលុបឈ្មោះប្រជាជលរដ្ឋប្រមាណ ១០ ភាគរយ ដែលបង្កឱ្យប៉ោងនេះពីក្នុងបញ្ជីរបោះឆ្នោត ដោយធ្វើការស្រាវជ្រាវដូចបានលើកឡើង ។ គជប មិនអាចប្រើបញ្ជីរបោះឆ្នោតដែលបោះរួចទេ ដោយសារច្បាប់មិនអាចឱ្យយើងប្រើបាន ។ ដូច្នេះ យើងនឹងស្រាវជ្រាវថា យកចំនួនប័ណ្ណពតិមាននៃអ្នកបោះឆ្នោតដែលចែកនៅសល់ធ្វើជាមូលដ្ឋាន ។ គជប មានគំរោងមួយធ្វើការឱ្យលំអិតជាទីបំផុត ដោយប្រគល់ការងារនេះទៅឱ្យ មេភូមិ ស្មៀន និងក្រុមប្រឹក្សាឃុំឱ្យទទួលខុសត្រូវ ។ ជំហានទី ១ គឺប្រគល់ឯកសារបញ្ជីរបោះឆ្នោត និងឯកសារមួយចំនួនដើម្បីឱ្យស្រង់ បន្ទាប់មកបិទផ្សាយជាសារធារណៈឱ្យបានច្រើនដងនិងសព្វទីកន្លែង ដើម្បីសុំលុបឈ្មោះកុំឱ្យប៉ះចំឈ្មោះប្រជាពលរដ្ឋគាត់នៅមានសិទ្ធិបោះឆ្នោត ។ ហើយគំរោងការណ៍នេះ គជប កំពុងចាប់ផ្តើមធ្វើសេចក្តីណែនាំនិងរៀបចំជំហានបន្តបន្ទាប់ ។ បញ្ហាខុសឈ្មោះអ្នកបោះឆ្នោតមានករណី ២ យ៉ាង គឺ ករណីទីមួយ ការបាត់ឈ្មោះ ហើយមួយទៀតនោះគឺខុសអក្ខរាវិរុទ្ធ ។ ការបាត់ឈ្មោះនេះ គឺកើតឡើងក្រោយពេលដែលយើងបានរៀបចំបញ្ជីរឈ្មោះតាមអក្ខរក្រម ។ ដូចខាង ខុមហ្វ្រែលបានលើកដែរថា ពេលស្មៀនសរសេរអក្សរខុសដូចជា លាយ និង ណយ ។ ដូចនេះការចំលងចូលទៅក្នុងបញ្ជីរក្នុងម៉ាស៊ីនកុំព្យូទ័រក៏ខុសដែរ ។ ឧទាហរណ៍ របស់គេ លាយ វាយបញ្ចូលជា ណយ ។ ដូច្នេះឈ្មោះ លាយ ត្រូវរត់ទៅកន្លែង ណយ នៅពេលចាត់តាមលំដាប់អក្សរ ។ ពេលនោះប្រជាពលរដ្ឋគិតថាបាត់ឈ្មោះ តាមពិតឈ្មោះគាត់មិនបាត់ទេ គ្រាន់តែប្តូរទីតាំងក្នុងបញ្ជីរ ។ បញ្ហានេះបណ្តាលមកពីការសរសេរខ្សោកខ្លាំងពេក ។ បញ្ហាមួយទៀតគឺឈ្មោះប្រហាក់ប្រហែលគ្នា ជួនកាល ស្មៀនរឺអ្នកកែគាត់មើលមិនច្បាស់ចំពោះឈ្មោះគេស្រដៀងឈ្មោះ ពេលកែទៅចំលើឈ្មោះអ្នកផ្សេង ហើយធ្វើឱ្យឈ្មោះម្នាក់នោះមានពីរ ហើយម្នាក់ទៀតត្រូវបាត់ឈ្មោះ ។ ករណីនេះក៏កើតមានច្រើនដែរ ។ មូលហេតុដែលឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីរបោះឆ្នោតខុសពីឈ្មោះក្នុងអត្តសញ្ញាណប័ណ្ណជាតិ ដោយសារអត្តសញ្ញាណប័ណ្ណជាតិធ្វើក្រោយ ហើយបញ្ជីរឈ្មោះអ្នកបោះឆ្នោតធ្វើមុន ។ បញ្ជីរឈ្មោះក្រោយទៀត កសាងឡើងដោយមិនចេញពីស្ថាប័នតែមួយនោះទេ ។ នៅតំបន់ខ្លះប្រជាពលរដ្ឋ ដូរឈ្មោះពេលធ្វើអត្តសញ្ញាណប័ណ្ណ ក្រោយពីមើលថាឈ្មោះគាត់មិនសូវល្អ សូម្បីតែសិស្សក៏ដូច្នោះដែរ ។

ទង្វើនេះនាំឱ្យឈ្មោះក្នុងអត្តសញ្ញាណប័ណ្ណនិងក្នុងបញ្ជីបោះឆ្នោតមានភាពខុសគ្នា ហើយវាធ្វើឱ្យមានការចេញទំរង់ ១០១៨ច្រើន ។ ហើយបញ្ហាការខុសឈ្មោះ គជប មានវិធានការណ៍ដូចលោក ម៉ា សុផល បានលើកឡើងហើយថា ដោយសារកាលពីមុនមកការសរសេរចំលងបញ្ជីបោះឆ្នោតដំបូងតំរូវក្នុងនីតិវិធីឱ្យចំលងមួយ ៤ ច្បាប់ ។ ពេលស្មៀន ចំលង ៤ច្បាប់ ធ្វើឱ្យពីមួយច្បាប់ទៅមួយច្បាប់អាចខុសគ្នា ។ មួយច្បាប់គាត់រក្សាទុក ហើយមួយ ច្បាប់ទៀតគាត់ យកទៅបិទ និង មួយច្បាប់ទៀតគាតក់បញ្ជូនមក គជប ។ ជួនកាល ទាំង ៤ច្បាប់អាចខុសគ្នាទាំងអស់ ។ ពេលខ្លះគាត់ វង្វេងគាត់យកច្បាប់ដែលមិនទាន់កែនោះបញ្ជូនមក គជប ដល់ពេល គជប បញ្ជូនបញ្ជីរទៅវិញ គាត់ថា គេកែរួចហើយ ហេតុអ្វី គជប មិនកែ ។ ស្មៀនគាត់ធ្វើការតែឯងហើយការងារច្រើន ជួនកាលគាត់រកគេចំលង ដូចជា កូនសិស្សចំលងពេលយប់ ។ វិធានាការណ៍ គឺ គជប បានរៀបចំហើយថា លើកនេះយើងបញ្ជូនបញ្ជីរបោះឆ្នោតតែមួយ ច្បាប់នោះទេ ដោយការបោះឆ្នោតលើកនេះអាចមានពេលវេលាវែង យើងអាចធ្វើទាន់ដោយបញ្ជូន ១ ច្បាប់ហើយឱ្យ ចំលងសរសេរតែមួយច្បាប់ហ្នឹង រួចបញ្ជូនមកវិញដល់ត្រឹមលេខាដ្ឋាន ហើយលេខាដ្ឋានថតចំលង ហើយបញ្ជូនទៅវិញ ដើម្បីបិទផ្សាយនិងប្រើប្រាស់ ។ គជប ធ្វើដូចនេះដើម្បីកុំឱ្យមានខុសគ្នាច្រើនក្នុងករណីហ្នឹង ។ ចំពោះការដូរ ការិយាល័យបោះបោះឆ្នោតវិញ គឺមិនមានកើតឡើងទេ ទោះជាច្បាប់បានកំណត់ថា ក្នុងការិយាល័យមួយមិន ឱ្យមានអ្នកបោះឆ្នោតលើសពី ៧០០ នាក់ទេ ហើយពេលលើសពី ៧០០នាក់ យើងត្រូវបំបែកការិយាល័យ ជាការិយាល័យផ្លូសក៏ដោយ ។ ការិយាល័យទាំងពីរនេះ គជប បានកំណត់រួច ហើយដាក់លេខកូដតែមួយទេ ឧទាហរណ៍ លេខ ០០១ ទៅជា ០០១ អា រឺ ០០១ បេ ហើយទីតាំងក៏ដាក់កន្លែងតែមួយដែរ ប៉ុន្តែ វាអាចមានបញ្ហាថា ប្រជាពលរដ្ឋគាត់គិតថា បើគាត់ដូរពីលេខ ០០១ គឺគាត់ត្រូវទៅ ០០២ ការពិតមិនមែន ០០២ ទេ ។ បើសិនជា ឆ្នាំនេះយើងដាក់ ០០១ អា ០០១ បេ ដល់ពេលឆ្នាំក្រោយ ប្រសិនបើនៅក្នុងខេត្តហ្នឹងមានការិយាល័យបោះឆ្នោតជាង ១០០០ គឺ លេខ បេ ឡើងដល់ជាង ១០០០ ដែរ ។ ទោះបីយ៉ាងណាក៏ការិយាល័យបោះឆ្នោតនៅរក្សាកន្លែងតែមួយ មិនមានការផ្លាស់ប្តូរទេ ។ ជួនកាលក៏មានការផ្លាស់ប្តូរកន្លែងខ្លះ ដូចជា នៅសាលាសំណាក់រឺនៅសលារៀនទ្រុឌទ្រោម ដល់ពេលដល់ថ្ងៃបោះឆ្នោតមិនអាចធ្វើការិយាល័យបោះឆ្នោតបានរឺមានផ្លាកគណបក្សនៅក្បែរ យើងត្រូវដកថយទៅ កន្លែងថ្មីនៅក្បែរកន្លែងចាស់ ។ ទីតាំងថ្មីមិនឆ្ងាយរហូតដល់រាប់រយម៉ែត្រដែរបើច្បាប់ថា ១០០ ម៉ែត្រគឺត្រូវសង់រោងនៅ កន្លែងនោះភ្លាម ហើយបិទផ្លាកសំគាល់ទៀតថា ការិយាល័យបោះឆ្នោតត្រូវបានដូរ ដាក់សញ្ញាសំគាល់មកដល់ ការិយាល័យថ្មីដែលយើងបានសង់ ។ បញ្ហា ការផ្តល់ប័ណ្ណពតិមាន ២ដង ដោយសារយើងយល់ថា នៅពេលដែលដូរ ការប្រើប្រាស់ប័ណ្ណបោះឆ្នោត ហើយទៅប្រើប្រាស់ឯកសារបញ្ជាក់អត្តសញ្ញាណ យើងព្យាករណ៍ថា វាមានការខុសគ្នា ឆ្ងាយណាស់ ដើម្បីសំរួល យើងត្រូវផ្តល់លើកទី១ដើម្បីឱ្យប្រជាពលរដ្ឋកែឈ្មោះតំរូវឯកសារបញ្ជក់អត្តសញ្ញាណ ។ ជួនកាលឈ្មោះរបស់គាត់ក្នុងបញ្ជីរបោះឆ្នោតត្រូវ ឯឈ្មោះក្នុងឯកសារបញ្ជាក់អត្តសញ្ញាណខុស ។ តែទោះបីយ៉ាងណា ក៏ដោយ យើងកែតំរូវឱ្យគាត់ធ្វើទៅតាមឯកសារបញ្ជាក់អត្តសញ្ញាណ ថាតើប្រជាពលរដ្ឋខ្លះមិនកែទេ ដោយសារ ឈ្មោះបញ្ជីរបោះឆ្នោតគាត់ត្រូវ ដូច្នេះគាត់សុំធ្វើទំរង់ ១០១៨ ។ ទង្វើនេះនាំឱ្យមានការចេញ ១០១៨ ច្រើនដែរ ។

នៅក្នុងការបោះឆ្នោតនាពេលខាងមុខនេះ គជប មានគំរោងផ្តល់ប័ណ្ណពតិមានឱ្យចប់មុនពេលបោះឆ្នោត ។ មួយទៀតគឺបញ្ហាឈ្មោះស្ទួន ខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវច្រើនដែរ តាមពិតឈ្មោះដែលយើងប្រើជាភាសាខ្មែរមានប្រហែលតែ ៥០០០ យ៉ាងច្រើន ប្រជាពលរដ្ឋមានរហូតដល់ទៅ ៧ លានជាង ។ ដូច្នេះឈ្មោះដែលដូច១គ្នាហើយមានស្ទួនទាំងថ្ងៃខែឆ្នាំកំនើត ដូចគ្នាក៏ច្រើនដែរ ។ ក្រោយពីការស្រាវជ្រាវមកយើងឃើញ ឧទាហរណ៍ ឈ្មោះពីរដូចគ្នា ពេលពិនិត្យឃើញថា មានមនុស្សម្នាក់ ។ ជួនកាល ឈ្មោះពីរមានមនុស្សពីរមែន គឺជាឈ្មោះមួយជាឈ្មោះលក់ឱ្យអ្នកផ្សេង ។ ឧទាហរណ៍ គាត់ជានាយកសាលាដល់ពេលគាត់បានឡើងឋានៈ គាត់បានលក់ឈ្មោះឱ្យប្អូនគាត់ដូច្នេះឈ្មោះគាត់និងប្អូនគាត់ដូចគ្នា ថ្ងៃខែឆ្នាំកំណើតក៏ដូចគ្នា ។ ពេលលុបមួយទៅ បងរឺប្អូនបាត់ឈ្មោះបាត់ឈ្មោះ។ នេះជាករណីពិបាកដោះស្រាយ ។ មួយទៀតជួនកាលឈ្មោះដែលយើងមើលឃើញក្នុងបញ្ជីរ គឺឈ្មោះអ្នកដែលស្លាប់ឧបមាថាគាត់ឈ្មោះ សុខ មេភូមិឃើញថា សុខ ស្លាប់បាត់ ហើយលុបឈ្មោះ សុខ មួយបាត់ តាមពិតឈ្មោះនៅក្នុងបញ្ជីរបោះឆ្នោតមិនមែនឈ្មោះ សុខ ផង គាត់ឈ្មោះ វឌ្ឍនៈ ទៅវិញ ។ ពេលលុបទៅប៉ះចំ សុខ ផ្សេងដែលធ្វើឱ្យបាត់ឈ្មោះ។ មួយទៀត សំនូមពរខាងគណបក្ស សម រង្ស៊ី លូ ហើយ គជប ក៏បានស្នើទៅរដ្ឋសភាឱ្យកំណត់រយៈពេលវែងជាងមុនហើយឆ្នាំនេះយើងបានបន្ថែមរយៈពេលចុះឈ្មោះ ពី ៣០-៣៥ថ្ងៃ ។ ខ្ញុំក៏គិតថាជាកាលំបាកដែរ ទំរង់ ១០១៨ ខ្ញុំស្រាវជ្រាវឃើញនៅខេត្ត រតនគីរី និងមណ្ឌលគីរី ប្រជាពលរដ្ឋពិបាករករូបថតមែនទែន តែមិនដឹងធ្វើម៉េចដោយសារតែច្បាប់តំរូវ ។ បើទំរង់ ១០១៨ មិនបិទរូបថត មិនបានទេ ព្រោះវាគ្មានអ្វីសំគាល់អត្តសញ្ញាណដែលអាចនាំឱ្យមានការបន្លំ ។ ហើយទំរង់ ១០១៨ នេះត្រូវតែចេញជាដាច់ខាត មិនអាចលុបចោលទេ ។ មូលហេតុប្រជាពលរដ្ឋអាចវង្វេងបាត់អត្តសញ្ញាណបណ្ណ័ពេលដល់ថ្ងៃបោះឆ្នោត ហើយជួនការជួបគ្រោះអគ្គីភ័យតាមគេហដ្ឋានដែលនាំឱ្យបាត់បង់អត្តសញ្ញាណបណ្ណ័សំរាប់បោះឆ្នោត ។ ហើយភាគរយ អ្នកទៅបោះឆ្នោតនៅខេត្តទាំងពីរគឺធ្លាក់ទាបមែនទែនជាងនេះទៅទៀត គឺគាត់ធ្វើការផ្លាស់ប្តូរគ្រប់ ៥ ឆ្នាំ គាត់ត្រូវដូរទៅភូមិផ្សេងត្រូវចុះឈ្មោះថ្មីនេះហើយដែលធ្វើឱ្យគាត់មានការពិបាកមួយទៀត ។

គជប កំពុងរៀបចំគំរោង Double Entry គឺ ឈ្មោះមួយ បញ្ចូលពីអ្នកបន្តគ្នា ។ បើអ្នកទាំង ២ បញ្ចូលត្រូវគ្នាប្រពន្ធ័ទិន្នន័យទទួលយក ។ វាបានន័យថា ការបញ្ចូលត្រឹមត្រូវ ។ បើអ្នកទី ១ បញ្ចូលហើយ រួចអ្នកទី ២ បញ្ចូលបន្តហើយបញ្ចូលខុសគ្នា វាអាចប្រាប់ឱ្យដឹងពីកំហុស ដូច្នេះត្រូវមានការកែតំរូវបន្ត ។ វិធានការផ្សេងទៀត ដើម្បីផ្ទៀងផ្ទាត់ឈ្មោះនោះ គឺ គជប និងតំឡើងខ្សែទូរសព្ទ័ ដើម្បីឱ្យប្រជាពលរដ្ឋអាចទាក់ទងផ្ទាល់ដើម កែឈ្មោះរបស់គាត់បានព្រមទាំងមានគេហទំព័រដែលមានឈ្មោះសំរាប់ផ្ទៀងផ្ទាត់ផងដែរ ។

## ៤. យោបល់តំណាងក្រសួងមហាផ្ទៃ

រយៈពេលពីថ្ងៃនេះដល់ថ្ងៃបោះឆ្នោតឆ្នាំ២០០៨ គឺមានប្រហែល១២ខែ ហើយដំណើរការចេញអត្តសញ្ញាណបណ្ណ័នៅមិនទាន់ចប់សព្វគ្រប់នៅឡើយ ថែមទាំងវាមិនបានតាមផែនការដែលគ្រោងឱ្យរួចរាល់នៅចុងឆ្នាំ២០០៦នោះផង ។ ការរាំងស្ទះមិនមែនស្ទះដោយសារដោយសារបច្ចេកទេសនោះទេ មូលហេតុចំបងគឺបណ្តាលមកពីប្រជាពលរដ្ឋ ដែលពាក់ពន្ធ័ទៅនឹងផ្លាស់ប្តូទីលំនៅ ស្លាប់ និងតំរូវការរបស់គាត់ជាដើម ។ ទោះបីជាក្រសួងមហាផ្ទៃអាចទុកចិត្តបានពីនិតិវិធីផ្តល់អត្តសញ្ញាណបណ្ណ័នេះក្តី ក៏មានករណីក្លែងក្លាយអត្តសញ្ញាណប័ណ្ណកើតមានឡើងដែរ ។ នៅឆ្នាំ២០០៤ ខេត្តកំពង់ស្ពឺចាប់បានជាង២០សន្លឹក ករណីក្លែងក្លាយអត្តសញ្ញាណបណ្ណ័សំរាប់ក្មេងៗអាយុប្រហែល១៤ រឺ១៥ ដើម្បីរកការងាររោងចក្រ ។ អត្តសញ្ញាណបណ្ណ័ក្លែងក្លាយមួយសន្លឹក ចំណាយអស់ ២០ ទៅ ៥០ ដុល្លារ ។ ភាពមិនប្រក្រតីនេះទាមទារឱ្យសហការគ្នាដើម្បីរកដំណោះស្រាយ ក្រសួងមហាផ្ទៃម្នាក់ឯង មិនអាចគ្រប់គ្រងបានទាំងស្រុងនោះទេ ។ ទន្ទឹមនឹងនេះដែរ ក្រសួងមហាផ្ទៃបានចាត់វិធានការណ៏តាមករណីជាក់ស្តែងដែលបានជួបប្រទះ ។ ទោះជាយ៉ាងនេះក្តី លក្ខណៈពិសេសរបស់អត្តសញ្ញាណបណ្ណ័ជាតិដែលត្រឹមត្រូវនោះ គឺមានលេខកូដសំងាត់នៅខាងខ្នង ហើយពេលវាអូសកាត់ម៉ាស៊ីនរបស់វា ទើបវាចេញ បើសិនជាអត្តសញ្ញាណបណ្ណ័ត្រឹមត្រូវ ។ បញ្ហាអ្នកមិនមកបោះឆ្នោតចំនួន ៣២ភាគរយ មិនមែនសុទ្ធតែអ្នកគ្មានអត្តសញ្ញាណបណ្ណ័ទាំងអស់នោះទេ ។ អ្នកទាំងនេះប្រហែលមានអត្តសញ្ញាណបណ្ណ័ពី ២០ ទៅ ២៥ភាគរយហើយ ប៉ុន្តែគាត់មិនមកបោះដោយសារមូលហេតុផ្សេងៗដែលបានលើកឡើងដោយវាគ្មិនខាងដើម ។ ដំណើរការចេញអត្តសញ្ញាណបណ្ណ័ចំពោះប្រជាពលរដ្ឋគ្រប់អាយុ ១៨ឆ្នាំ ត្រឹមថ្ងៃបោះឆ្នោតអាចមិនទាន់ដើម្បីបោះឆ្នោតខាងមុខ ដូច្នេះ ស្នើឱ្យ គជប ពិចារណាលើបង្កាន់ដៃដែលបញ្ជាក់ថាមានតំលៃស្មើនឹងអត្តសញ្ញាណបណ្ណ័ដើម្បីយកទៅចុះឈ្មោះបោះឆ្នោត ។ ដំណើរការផ្តល់អត្តសញ្ញាណបណ្ណ័ពុំអាចកំណត់ពីថ្ងៃបញ្ចប់បានទេ ។ ការប្រឹងប្រែងផ្តល់ឱ្យទាន់ចំពោះអ្នកគ្រប់អាយុ នៅតែបន្តដោយផ្លាស់ប្តូរនិតិវិធីតាមភូមិសាស្រ្ត ។ ជួនកាលភូមិសាស្រ្តខ្លះមន្ត្រីប៉ូលីសស្ពាយកុំព្យូទ័រ និងឧបករណ៏ទៅដល់ភូមិប្រជាពលរដ្ឋ ។ ប៉ុន្តែ ប្រជាពលរដ្ឋនៅមិនព្រមធ្វើ ជាពិសេសខេត្តខាងភូមិភាគឥសាន្តដែលភូមិសាស្រ្តលំបាក និងមាជនជាតិច្រើន ។ ករណីគាត់មកធ្វើអត្តសញ្ញាណបណ្ណ័វិញ លុះត្រាតែគាត់ត្រូវការ ឧទាហរណ៏ គាត់ចង់លក់ដី រឺជួនកាលបញ្ហាកូនចៅធានាទៅបរទេស ហើយរដ្ឋអំណាចភូមិឃុំ សួររកអត្តសញ្ញាណបណ្ណ័ទើបគាត់ទៅធ្វើគាត់ទៅធ្វើព្រមទាំងបង់កំរៃក្រៅទៀតផង ដែលអាចមានចំនួនបួនដប់ម្ភៃដុល្លារ ។ រដ្ឋាភិបាលមិនយកកំរៃចំពោះការធ្វើអត្តសញ្ញាណបណ្ណ័នោះទេ ប៉ុន្តែករណីមួយចំនួន មន្ត្រីប៉ូលីសបានទាមទារប្រាក់កំរៃដែលជាប្រការមិនត្រឹមត្រូវ ។ បញ្ហាខុសឈ្មោះតែងតែមាន ដោយការបញ្ចូល ទិន្នន័យទៅក្នុងកុំព្យូទ័រ ។ ជួនកាលកំហុសមានតាំងពីមន្ត្រីប៉ូលីសសរសេរខុស ហើយអ្នកបញ្ចូលខុសខ្លះទៀត ។ សរុបមកដល់ដាច់ឆ្នាំ២០០៦នេះ ជាងមួយម៉ឺនអត្តសញ្ញាណបណ្ណ័បានធ្វើខុស ដូចជាឈ្មោះ និងថ្ងៃខែឆ្នាំកំណើត ហើយបញ្ហាខុសធ្ងន់គឺភេទ ។

ការឃឹតយ៉ាវមិនបានទទួលអត្តសញ្ញាណបណ្ណ័រយៈពេល៥-៦ខែ បន្ទាប់ពីធ្វើរួច ប្រជាពលរដ្ឋអាចធ្វើថ្មីម្តងទៀត ព្រោះករណីជាច្រើនអាចបាត់សំនុំឯកសារទិន្នន័យ ។ ដោយសារទង្វើមិនស្របតាមការណែនាំ ហើយមានការបង់ប្រាក់ក្រៅផ្លូវការ អត្តសញ្ញាណបណ្ណ័នេះអាចត្រូវគេចាត់ចែងធ្វើឱ្យអ្នកដែលមិនមានអត្តសញ្ញាណ សញ្ជាតិខ្មែរគ្រប់លក្ខណៈ ។ ចំពោះរឿងនេះ វាពាក់ពន្ធ័នឹងមន្ត្រីប៉ូលីសដែលយកកំរៃក្នុងការធ្វើអត្តសញ្ញាណបណ្ណ័ ។ វាជារឿងច្រឡោះប្រហោងដែលយើងត្រូវបន្តជជែកគ្នានិងដោះស្រាយដើម្បីឱ្យការងារឱ្យវាសុក្រិត ។ ដោយយោងទៅ លើការលំបាកនិងទាមទារពេលវេលាធ្វើអត្តសញ្ញាណបណ្ណ័ ក្រសួងស្នើឱ្យ UNDP សុំរួលម៉ាស៊ីនថត និងជួយអ្នកបច្ចេកទេស ពីព្រោះចុងឆ្នាំនេះដំណើរការចេញអត្តសញ្ញាណបណ្ណ័គំរូថ្មី គឺចេញពីបណ្តាខេត្ត ដែលខេត្តជាអ្នកបោះពុម្ពចេញ និងចែកជូនប្រជាពលរដ្ឋ ។ ជាចុងឆ្នាំនេះ យើងអាចចេញបញ្ចាប់ស្ថិតិចាស់ដែលនៅសល់ជាង ៣0ម៉ឺននាក់ទៀត ។ ការចេញអត្តសញ្ញាណបណ្ណ័ក៏ពាក់ពន្ធ័នឹងស្ថិត្តិដែរ ហើយក៏យើងមិនបានធ្វើម៉តចត់ដែរ ។ ឧទាហរណ៍ គ្រួសារមួយមាន កូនស្រីម្នាក់រៀបការ ហើយទៅរស់នៅបរទេសបាត់ជាមួយប្តី ។ បើតាមគោលការណ៏ណែនាំ បើឈប់រស់នៅ ៦ខែ ត្រូវលុបឈ្មោះចេញពីបញ្ជីស្នាក់នៅ និងបញ្ជីគ្រួសារ ។ រយៈពេល ១-២ឆ្នាំ កូនស្រីនោះអាចចូលសញ្ជាតិ ពេលនោះគាត់មានសិទ្ធិមកលេងកម្ពុជា ។ បើសិនជាគាត់មិនបានលុបឈ្មោះ គាត់ក៏អាចធ្វើអត្តសញ្ញាណបណ្ណ័ និងធ្វើសំបុត្រកំណើតបានដែរ ។ ដូច្នេះ ដំណើរការចេញអត្តសញ្ញាណបណ្ណ័សញ្ជាតិខ្មែរ មិនត្រឹនត្រូវតាមគោលការណ៏ណែនាំទាំងអស់នោះទេ ។

~ចប់~